# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ២១៥២ អក
ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១
សាលក្រមលេខ៖ ៧៨ "ណ"
ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២

# តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកណ្តាលបានបើកសវនាការនៅសាលាសវនាការ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted]ធានក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ជាចៅក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ជាព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

**មេធាវីការពារសិទ្ធិ**

កញ្ញា [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ
លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខៈ ២១៥២ អ.ក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សិទ្ធិ ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មានទីកន្លែងកំណើត [redacted] ខេត្តព្រៃវែង និងទីលំនៅបច្ចុប្បន្ននៅភូមិព្រែកឬស្សី សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សាក់ (រ) ម្តាយឈ្មោះ [redacted] ឡុង (រ) នៅលីវ ទោសពីមុនគ្មាន ជានីតិជន (ក្នុងឃុំ) ។

ជាប់ចោទពីបទៈ រួមភេទជាមួយអនីតិជនក្រោយអាយុ១៥ឆ្នាំ ប្រព្រឹត្តនៅផ្ទះជនរងគ្រោះភូមិព្រែកឬស្សី សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៥-១០-២០២១។ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បញ្ញា ភេទប្រុស អាយុ ៣៩ ឆ្នាំ សញ្ជាតិខ្មែរ និងជនរងគ្រោះឈ្មោះ [redacted] បញ្ញានុត ភេទស្រី អាយុ១៤ឆ្នាំ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ចាម និងមានទីលំនៅបច្ចុប្បន្ននៅភូមិព្រែកឬស្សី សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។

*អង្គហេតុនៃរឿងមានដូចតទៅ៖*

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ២២ និង ២២ នាទីនៅចំណុចបន្ទប់ជនរងគ្រោះ ស្ថិតនៅភូមិព្រែកឬស្សី សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល មានករណី រួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] សិទ្ធ ភេទប្រុស អាយុ១៩ឆ្នាំ ដោយជនរងគ្រោះឈ្មោះ [redacted] បញ្ញានុត ភេទស្រី អាយុ១៤ឆ្នាំ និងជនសង្ស័យបានស្រលាញ់គ្នារយៈពេល



Scanned with CamScanner

ពីរខែហើយ ក្រោយមកនៅពេលម្តាយឪពុកជនរងគ្រោះមិននៅផ្ទះ ជនសង្ស័យបានទៅលេងដល់បន្ទប់គេងរបស់ជនរងគ្រោះ និងបាននិយាយត្រូវរ៉ូវគ្នា រួចបានរួមភេទជាមួយឈ្មោះ [redacted] បញ្ញានុត ជាច្រើនដង។ ក្រោយមកនៅពេលដែលឪពុកម្តាយរបស់ឈ្មោះ [redacted] បញ្ញានុត បានដឹងអំពីរឿងហេតុដែលឈ្មោះ [redacted] សិទ្ធ រួមភេទជាមួយកូនស្រីរបស់ខ្លួន ក៏បានដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលព្រែកឫស្សីតែម្តង។

-បានឃើញ ដីកាដំណោះស្រាយលេខ: ២៤៧ ដកជស ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: ២៨២ ដកចត ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## នាពេលសវនាការ

១-ចម្លើយជនជាប់ចោទឈ្មោះ [redacted] សិទ្ធ បានឆ្លើយថា៖ ខ្លួនមានទំនាក់ទំនងស្រឡាញ់គ្នារយៈពេល ០២ ខែមកហើយ។ និងធ្លាប់បានរួមភេទជាច្រើនដងមកហើយដែរ គឺនៅផ្ទះសង្សាររបស់ខ្លួន។ ពីមុនខ្លួនមិនដែលធ្លាប់ជាប់ពន្ធនាគារនោះទេ។ ចំពោះថ្នាំញៀនខ្លួនធ្លាប់ប្រើប្រាស់ដែរ។ ពេលដែលខ្លួនរួមភេទជាមួយសង្សាគឺដោយស្មគ្រ័ចិត្តទៅវិញទៅមក។ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នៅវេលាម៉ោង ២២ និង ២០ នាទី ខ្លួន និងឈ្មោះ [redacted] បញ្ញានុត ភេទស្រី អាយុ១៤ឆ្នាំ ត្រូវជាសង្សាររបស់ខ្លួន បាននិយាយគ្នារួចហើយក៏បានចូលក្នុងបន្ទប់រួចបានរួមភេទជាមួយគ្នាម្តងទៀតនៅក្នុងផ្ទះរបស់ឈ្មោះ [redacted] បញ្ញានុត នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ក្រុមគ្រួសារឈ្មោះ [redacted] បញ្ញានុត ដឹងបានដាក់ពាក្យបណ្តឹង បន្ទាប់មកសមត្ថកិច្ចបានឃាត់ខ្លួនមកប៉ុស្តិ៍រដ្ឋបាលព្រែកឫស្សី ដើម្បីសួរនាំតែម្តង។

២-ចម្លើយជនរងគ្រោះឈ្មោះ [redacted] បញ្ញានុត បានឆ្លើយថា៖ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ រូបខ្លួនមានទំនាក់ទំនងគ្នាជាមួយឈ្មោះ [redacted] សិទ្ធិ ហៅ ទុំ ពេលនោះខ្លួនបានឆាតទូរស័ព្ទជាមួយគ្នារាល់ថ្ងៃ ដោយឈ្មោះបងសិទ្ធិ បានប្រាប់ថាស្រឡាញ់ខ្លួន តែខ្លួនមិនទាន់បានប្រាប់គាត់វិញទេ ទាល់តែយូរមកទៀត ទើបខ្លួនប្រាប់គាត់វិញ។ បន្ទាប់មកឈ្មោះបងសិទ្ធិបានមកទាក់ទង មកខ្លួនដើម្បីនិយាយគ្នាលេងនៅមុខផ្ទះរៀងរាល់ថ្ងៃ។ នៅថ្ងៃទីមិនចាំឈ្មោះ [redacted] សិទ្ធិ ហៅ ទុំ បានសុំខ្លួនចូលទៅលេងក្នុងផ្ទះតែខ្លួនបានប្រកែកថាខ្លាចប៉ាម៉ាក់គាត់ឃើញ ប៉ុន្តែឈ្មោះ [redacted] សិទ្ធិថាចូលទៅតែមួយភ្លែតទេ ពេលគាត់ចូលទៅហើយគាត់ឃើញប៉ាម៉ាក់ខ្លួនគេងលក់បាត់ គាត់ក៏ដើរទៅបន្ទប់របស់ខ្លួន វេលាម៉ោង ១១ និង ៣០ នាទី ពេលនោះបងសិទ្ធិហៅទុំ បានប្រាប់ខ្លួនថា ស្រឡាញ់ខ្លួន ហើយគាត់បានអោបថើបខ្លួន ពេលនោះពួកខ្លួនបានរួមភេទជាមួយគ្នាបានមួយដង ហើយមួយសន្ទុះក្រោយមកបងសិទ្ធិហៅទុំ ក៏បានមកសុំរួមភេទទៀត តែខ្លួនប្រាប់គាត់ថាអត់ទេ ព្រោះខ្លួនខ្លាចប៉ាម៉ាររបស់ខ្លួនដឹង។ ក្រោយមកឈ្មោះ សិទ្ធិ ហៅ ទុំ តែងតែណាត់ជួបខ្លួននិយាយគ្នាលេង និងរួមភេទជាមួយគ្នាជាញឹកញ៉ាប់។ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១០ និង ៣០ នាទី [redacted] សិទ្ធិ ហៅទុំ បានផ្ទះរបស់ខ្លួន ហើយបានរួមភេទជាមួយខ្លួនម្តងទៀត ពេលនោះប៉ាកម៉ាក់របស់ខ្លួនគាត់ទៅស្រុកមុខកំពូល ពួកខ្លួនកំពុងតែគេងជាមួយគ្នា។ លុះព្រឹកឡើងថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០២១ ពេលនោះមីងរបស់ខ្លួនគាត់បានមកផ្ទះខ្លួន ហើយស្រែកឱ្យខ្លួនបើកទ្វា រួច ក៏បានចូលមកមើលហើយគាត់ក៏បានចេញទៅក្រៅបាត់ [redacted] សិទ្ធិ ហៅ ទុំ ក៏ចេញទៅតាមក្រោយ។ ពេលក្រោយមកខ្លួនក៏ឮថាមីងខ្លួនបានប្រាប់ប៉ាររបស់ខ្លួន ពេលនោះប៉ា ខ្លួនបានហៅមកសួរ ពេលនោះខ្លួន បានប្រាប់ប៉ាថាខ្លួនស្រឡាញ់បងសិទ្ធិហៅទុំ និងបានរួមភេទជាមួយ គ្នាហើយ។

៣-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បញ្ញា បានឆ្លើយថា: កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ រឿងនេះជាករណីលួងលោមបង្ខំទៅលើកូនស្រីខ្លួនឈ្មោះ [redacted] បញ្ញានុត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ដំបូងឡើយចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនមានការចាប់អារម្មណ៍ លើកូនស្រី

របស់ខ្លួនឈ្មោះ [redacted] បញ្ញានុត គឺមានសភាពស្លេកស្លាំងឈឺពោះនោមទល់ចុកស្បូន លុះមកដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ មានអ្នកជិតខាងប្រាប់ថា ឱ្យខ្លួនប្រយ័ត្នកូនស្រីរបស់ខ្លួនជាមួយបុគ្គលឈ្មោះ [redacted] សិទ្ធិ ឃើញឧស្សាហ៍ចេញចូលផ្ទះរបស់ខ្លួន ក្រោយមកខ្លួនក៏បានតាមដានដឹង និងហៅកូនស្រី ខ្លួនមក សួរនាំ ហើយបានប្រាប់ថាឈ្មោះ [redacted] សិទ្ធិ ពិតជាបានបង្ខិតបង្ខំរួមភេទពិតប្រាកដមែន និងជាច្រើនដងមក ហើយ។

៤-ចម្លើយសាក្សីឈ្មោះ[redacted]ផានិត បានឆ្លើយថាៈ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ខ្លួនបានមកលក់ផ្លែឈើនៅផ្សារព្រែកឬស្សី លុះនៅម៉ោង ១០ ព្រឹក ប្តីខ្លួនបានខលទូរស័ព្ទមកប្រាប់ខ្លួនថា កូនយើងត្រូវអាទុំ ([redacted] សិទ្ធិ) ចូលមកក្នុងផ្ទះហើយបានខូចខ្លួនជាមួយវាហើយ ឥឡូវខ្លួននាំមករកាកោងហើយ។ ក្រោយមកនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ខ្លួន និងប្តីរបស់ខ្លួន បានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ព្រែកឬស្សីដើម្បីឱ្យសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

៥-តំណាងអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថាៈ មានភស្តុតាង និងពិរុទ្ធភាព លើជនជាប់ចោទឈ្មោះ [redacted] សិទ្ធ ជាប់ចោទពីបទៈ **រួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ** ប្រព្រឹត្តនៅផ្ទះជនរងគ្រោះភូមិព្រែកឬ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៥-១០-២០២១។ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

**ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**<u>យល់ឃើញថាៈ</u>**

### ក.អំពីពិរុទ្ធភាព

១-តាមដីកាដំណោះស្រាយលេខៈ ២៤៧ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ បានបញ្ជូនជនត្រូវចោទឈ្មោះ [redacted] សិទ្ធ ពីបទអំពើ **រួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ** ប្រព្រឹត្តនៅផ្ទះជនរងគ្រោះ ភូមិព្រែកឬស្សី សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៥-១០-២០២១។ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២-ចម្លើយជនជាប់ចោទឈ្មោះ [redacted] សិទ្ធ បានឆ្លើយថាៈ ខ្លួនមានទំនាក់ទំនងស្រឡាញ់គ្នារយៈពេល ០២ ខែមកហើយ។ និងធ្លាប់បានរួមភេទជាច្រើនដងមកហើយដែរ គឺនៅផ្ទះសង្សាររបស់ខ្លួន។ ពីមុនខ្លួនមិនដែលធ្លាប់ជាប់ពន្ធនាគារនោះទេ។ ចំពោះថ្នាំញៀនខ្លួនធ្លាប់ប្រើប្រាស់ដែរ។ ពេលដែលខ្លួនរួមភេទជាមួយសង្សាគឺដោយស្មគ្រ័ចិត្តទៅវិញទៅមក។ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ នៅវេលាម៉ោង ២២ និង ២០ នាទី ខ្លួន និងឈ្មោះ [redacted] បញ្ញានុត ភេទស្រី អាយុ១៤ឆ្នាំ ត្រូវជាសង្សាររបស់ខ្លួនបាននិយាយគ្នារួចហើយក៏បានចូលក្នុងបន្ទប់រួចបានរួមភេទជាមួយគ្នាម្តងទៀតនៅក្នុងផ្ទះរបស់ឈ្មោះ [redacted] បញ្ញានុត នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ក្រុមគ្រួសារឈ្មោះ [redacted] បញ្ញានុត ដឹងបានដាក់ពាក្យបណ្តឹងបន្ទាប់មកសមត្ថកិច្ចបានឃាត់ខ្លួនមកប៉ុស្តិ៍រដ្ឋបាលព្រែកឬស្សី ដើម្បីសួរនាំ តែម្តង។

៣-ចម្លើយជនរងគ្រោះឈ្មោះ [redacted] បញ្ញានុត បានឆ្លើយថាៈ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ រូបខ្លួនមានទំនាក់ទំនងគ្នាជាមួយឈ្មោះ[redacted]សិទ្ធិ ហៅ ទុំ ពេលនោះខ្លួនបានឆាតទូរស័ព្ទជាមួយគ្នារាល់ថ្ងៃដោយឈ្មោះបងសិទ្ធិ បានប្រាប់ថាស្រឡាញ់ខ្លួន តែខ្លួនមិនទាន់បានប្រាប់គាត់វិញទេ ទាល់តែយូរមកទៀត ទើបខ្លួនប្រាប់គាត់វិញ។ បន្ទាប់មកឈ្មោះ[redacted]សិទ្ធិបានមកទាក់ទង មកខ្លួនដើម្បីនិយាយគ្នាលេងនៅមុខផ្ទះរៀងរាល់ថ្ងៃ។ នៅថ្ងៃទីមិនចាំឈ្មោះ [redacted]សិទ្ធិ ហៅ ទុំ បានសុំខ្លួនចូលទៅលេងក្នុងផ្ទះតែខ្លួនបានប្រកែកថាខ្លាចប៉ាម៉ាក់គាត់ឃើញ ប៉ុន្តែឈ្មោះ [redacted]សិទ្ធិថាចូលទៅតែមួយភ្លែតទេ ពេលគាត់ចូលទៅ

ហើយគាត់ឃើញប៉ាម៉ាក់ខ្លួនគេងលក់បាត់ គាត់ក៏ដើរទៅបន្ទប់របស់ខ្លួន វេលាម៉ោង ១១ និង ៣០ នាទី ពេលនោះបងសិទ្ធិហៅទុំ បានប្រាប់ខ្លួនថា ស្រឡាញ់ខ្លួន ហើយគាត់បានអោបថើបខ្លួន ពេលនោះពួកខ្លួនបានរួមភេទជាមួយគ្នាបានមួយដង ហើយមួយសន្ទុះក្រោយមកបងសិទ្ធិហៅទុំ ក៏បានមកសុំរួមភេទទៀត តែខ្លួនប្រាប់គាត់ថាអត់ទេ ព្រោះខ្លួនខ្លាចប៉ាម៉ារបស់ខ្លួនដឹង។ ក្រោយមកឈ្មោះ សិទ្ធិ ហៅ ទុំ តែងតែណាត់ជួបខ្លួននិយាយគ្នាលេង និងរួមភេទជាមួយគ្នាជាញឹកញ៉ាប់។ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ វេលាម៉ោង ១០ និង ៣០ នាទី បងសិទ្ធិ ហៅទុំ បានផ្ទះរបស់ខ្លួន ហើយបានរួមភេទជាមួយខ្លួនម្តងទៀត ពេលនោះប៉ាកម៉ាក់របស់ខ្លួនគាត់ទៅស្រុកមុខកំពូល ពួកខ្លួនកំពុងតែគេងជាមួយគ្នា។ លុះព្រឹកឡើងថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ពេលនោះមីងរបស់ខ្លួនគាត់បានមកផ្ទះខ្លួន ហើយស្រែកឱ្យខ្លួនបើកទ្វា រួច ក៏បានចូលមកមើលហើយគាត់ក៏បានចេញទៅក្រៅបាត់ [redacted] សិទ្ធិ ហៅ ទុំ ក៏ចេញទៅតាមក្រោយ។ ពេលក្រោយមកខ្លួនក៏ឮថាមីងខ្លួនបានប្រាប់ប៉ារបស់ខ្លួន ពេលនោះប៉ា ខ្លួនបានហៅមកសួរ ពេលនោះខ្លួន បានប្រាប់ប៉ាថាខ្លួនស្រឡាញ់បងសិទ្ធិហៅទុំ និងបានរួមភេទជាមួយ គ្នាហើយ។

៤-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បញ្ញា បានឆ្លើយថាៈ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ រឿងនេះជាករណីលួងលោមបង្ខំទៅលើកូនស្រីខ្លួនឈ្មោះ [redacted] បញ្ញានុត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ដំបូងឡើយ ចាប់ពីខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនមានការចាប់អារម្មណ៍ លើកូនស្រីរបស់ខ្លួនឈ្មោះ [redacted] បញ្ញានុត គឺមានសភាពស្លេកស្លាំងឈឺពោះនោមទល់ចុកស្បូន លុះមកដល់ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ មានអ្នកជិតខាងប្រាប់ថា ឱ្យខ្លួនប្រយ័ត្នកូនស្រីរបស់ខ្លួនជាមួយបុគ្គលឈ្មោះ [redacted] សិទ្ធិ ឃើញឧស្សាហ៍ចេញចូលផ្ទះរបស់ខ្លួន ក្រោយមកខ្លួនក៏បានតាមដានដឹង និងហៅកូនស្រី ខ្លួនមកសួរនាំ ហើយបានប្រាប់ថា ឈ្មោះ [redacted] សិទ្ធិ ពិតជាបានបង្ខិតបង្ខំរួមពិតប្រាកដមែន និងជាច្រើនដងមកហើយ។

៥-ចម្លើយសាក្សីឈ្មោះ [redacted] ផានិត បានឆ្លើយថាៈ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ខ្លួនបានមកដល់ផ្លែឈើនៅផ្សារព្រែកឫស្សី លុះនៅម៉ោង ១០ ព្រឹក ប្តីខ្លួនបានខលទូរស័ព្ទមកប្រាប់ខ្លួនថា កូនយើងត្រូវអាទុំ ([redacted] សិទ្ធិ) ចូលមកក្នុងផ្ទះហើយបានខូចខ្លួនជាមួយវាហើយ ឥឡូវខ្លួននាំមករកាកោងហើយ។ ក្រោយមកនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ខ្លួន និងប្តីរបស់ខ្លួន បានទៅដាក់ពាក្យបណ្តឹង នៅប៉ុស្តិ៍ព្រែកឫស្សីដើម្បីឱ្យសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

៦-ផ្អែកតាមភស្តុតាងផ្សេងៗ ឱ្យដឹងថាជនជាប់ចោទឈ្មោះ [redacted] សិទ្ធ ពិតជាបានប្រព្រឹត្តអំពើរួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] សិទ្ធ ភេទប្រុស អាយុ១៩ឆ្នាំ ដោយជនរងគ្រោះឈ្មោះ [redacted] បញ្ញានុត ភេទស្រី អាយុ១៤ឆ្នាំ និងជនសង្ស័យបានស្រលាញ់គ្នារយៈពេល២ពីរខែហើយ ក្រោយមកនៅពេលម្តាយឪពុកជនរងគ្រោះមិននៅផ្ទះ ជនសង្ស័យបានទៅលេងដល់បន្ទប់គេងរបស់ជនរងគ្រោះ និងបាននិយាយត្រូវរ៉ូវគ្នា រួចបានរួមភេទជាមួយឈ្មោះ [redacted] បញ្ញានុត ជាច្រើនដង ពិតប្រាកដមែន។

៧-អំពើជនជាប់ចោទឈ្មោះ [redacted] សិទ្ធ មានចេតនាទុច្ចរិត ដែលចាត់ទុកជាបទៈ រួមភេទជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ តាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

៨-ជនជាប់ចោទឈ្មោះ [redacted] សិទ្ធ ជាសមត្ថជនមានស្មារតីធម្មតា អាចយល់ដឹងពីបច្ច័យ និងព្យសនកម្ម ដែលបានកើតឡើងពីអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

៩-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] សិទ្ធ បានធ្វើឱ្យប៉ះពាល់របៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គមដូចនេះត្រូវ តែទទួលខុសត្រូវចំពោះមុខច្បាប់។



Scanned with CamScanner

១០-មានភស្តុតាងគ្រប់គ្រាន់ បញ្ជាក់ពីពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] សិទ្ធ (មានសាវតាជាតិគ្រប់គ្រាន់ដូចខាងលើ) ពីបទអំពើ រួមភេទជាមួយអនីតិជនក្រោយអាយុ១៥ឆ្នាំ ប្រព្រឹត្តនៅផ្ទះជនរងគ្រោះ ភូមិព្រែកឬ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៥-១០-២០២១។ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

១១-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បញ្ញា បានឆ្លើយនៅចៅក្រមស៊ើបសួរ សុំទាមទារសំណងជម្ងឺចិត្តចំនួន USD ៨០០០ (ប្រាំបីពាន់ដុល្លារអាមេរិក )និងសុំផ្តន្ទាទោសជនល្មើសតាមច្បាប់ ដូចអាចឱ្យតុលាការ សម្រេច និងពិចារណាបាន។

ខ-អំពីទោស៖ គប្បីតុលាការសម្រេច និងលើកយកមកពិចារណាតាមមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

## ហេតុដូច្នេះ-តុលាការ

## សម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សិទ្ធ (សាវតាជាតិគ្រប់គ្រាន់ដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៥ ឆ្នាំ (ប្រាំឆ្នាំ) តែទោសនេះអនុវត្តក្នុងពន្ធនាគារកំណត់រយៈពេល ២ ពីឆ្នាំ និង ៦ ខែ (ប្រាំមួយខែ)។ ។

ពីបទ៖ រួមភេទជាមួយអនីតិជនក្រោយអាយុ១៥ឆ្នាំ ប្រព្រឹត្តនៅផ្ទះជនរងគ្រោះភូមិព្រែកឬ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៥-១០-២០២១។ បទល្មើសព្រហ្មទណ្ឌ ដែលបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ៤២ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២-បង្គាប់ឱ្យជនត្រូវចោទសងសំណងជម្ងឺចិត្តចំនួន ៦,000.000 លានរៀល (ប្រាំមួយលានរៀល) មកឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បញ្ញា ការទាមទារលើសពីនេះត្រូវច្រានចោល។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សិទ្ធ ,ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បញ្ញា និងជនរងគ្រោះឈ្មោះ [redacted] បញ្ញានុត។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ចៅក្រមជំនុំជម្រះ |
|---|---|---|---|

ហត្ថលេខា និងត្រា៖ [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ២កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កណ្តាល,ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២
**ក្រឡាបញ្ជី**
[redacted]

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]